មហាអយ្យការអម

សាលាឧទ្ធរណ៍ភ្នំពេញ

លេខ ១៦ រប -៩៤

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ

**<u>សូមជម្រាបមក</u>**

**លោកប្រធាតុលាការ រាជធានីភ្នំពេញ**

<u>សូមជ្រាប។</u>

**<u>*កម្មវត្ថុ:*</u>** ការអនុវត្តច្បាប់នីតិវិធីព្រហ្មទណ្ឌ ។

**<u>*យោង:*</u>** លិខិតបង្គាប់ការ ក្រសួងយុត្តិធម៌លេខ ៩៤ ប.ក.៩៤ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៩៤ ។

ខ្ញុំសូមជម្រាបរំលឹកលោកថា ច្បាប់នីតិវិធីព្រហ្មទណ្ឌ ដែលអនុម័តដោយរដ្ឋសភានៃរដ្ឋកម្ពុជាកាលពី ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣ មានអានុភាពអនុវត្តភ្លាមៗ ហើយថយក្រោយទៀត ។

ដូច្នេះសំណុំរឿងដែលបំពេញតាមទម្រង់នីតិវិធី ឆ្នាំ១៩៨៦ ហើយពុំទាន់មានសេចក្ដីសម្រេចពីតុលាការជាស្ថាពរ ពុំមានន័យត្រូវអនុវត្តបន្តទៅទៀតឡើយ ផ្ទុយទៅវិញត្រូវតែមានការសើរើអនុវត្តតាមបញ្ញត្តិមាត្រា៦៧ កពពទ ដែលចែងថា: រដ្ឋអាជ្ញា នឹង អាចប្រើនីតិវិធីចោទប្រកាន់ផ្ទាល់ទៅតុលាការតែម្ដង នោះបានតែក្នុងករណីដែលជនជាប់ចោទអាចនឹងត្រូវផ្ដន្ទាទោសដាក់គុកដែលអតិបរមានៃទោសមិនលើសពី១ឆ្នាំ បើពុំនោះទេរដ្ឋអាជ្ញាត្រូវបញ្ជូនរឿងទៅចៅក្រមស៊ើបអង្កេតសិន និងបញ្ញត្តិមាត្រា៦៨ កពពទ និង តទៅ ។

អាស្រ័យហេតុនេះ ខ្ញុំសូមលោកចាត់ការតម្រូវដោយមានការគោរពច្បាប់តាមន័យដូចបានជម្រាបខាងលើ ដើម្បីបានត្រឹមត្រូវជាប្រញាប់តទៅ ។

សូមកត់សម្គាល់ថា ដីកាចាប់ខ្លួនចេញដោយស្នងការនគរបាល ឬ ព្រះរាជអាជ្ញាគ្មានឥទ្ធិពលអនុវត្តឡើយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៤

អគ្គព្រះរាជអាជ្ញា

**ហង់រ៉ូ វ៉ាគេន**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌

-លោកស្រីជំនាញការ

-ព្រះរាជអាជ្ញាអមតុលាការរាជធានីភ្នំពេញ